**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ : ៤៤២១ មស.ក្រ

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន**

**កម្មវត្ថុ** :-សំណើសុំពន្លឿនការដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ ២០១៦ ជូនមន្ត្រីរាជការស៊ីវិល ។

**យោង** :-ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

-សេចក្តីជូនដំណឹងលេខ ៥៧៣ មស.សជណ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីការដំឡើងថ្នាក់ ឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិល សម្រាប់ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ។

-លិខិតលេខ ៦០០ មស.នក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីនីតិវិធីក្នុងការបំពេញបែបបទមួយចំនួន លើការដំឡើងថ្នាក់ជូនមន្ត្រីរាជការស៊ីវិល របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

ខ្ញុំមានកិត្តិយស សូមជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នមេត្តាជ្រាបថា ដើម្បីឱ្យការដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ២០១៦ ជូនមន្ត្រីរាជការស៊ីវិល ឱ្យបានទាន់ពេលវេលា និងជាផលប្រយោជន៍ដល់មន្ត្រីរាជការ ក្រសួងមុខងារសាធារណៈ សូមជម្រាបជូនគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធមេត្តាយកចិត្តទុកដាក់អនុវត្តលើការដំឡើងថ្នាក់ ឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិល តាមវេនជ្រើសរើស និងវេនអតីតភាពការងារឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់ក្នុងការចូលរួមសហការអនុវត្តន៍។

ក្រសួងមុខងារសាធារណៈ ឈប់ទទួលការស្នើសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ ២០១៦ **ត្រឹមថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦** ជាកំហិត ក្រសួង ស្ថាប័ននីមួយៗត្រូវភ្ជាប់ឯកសារពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ និងឯកសារដំឡើងថ្នាក់ ឋានន្តរស័ក្តិចុងក្រោយមកជាមួយផង ។ ក្នុងករណីមានការយឺតយ៉ាវ ឬខកខាន តាមកាលបរិច្ឆេទខាងលើ ក្រសួងមុខងារសាធារណៈ នឹងធ្វើរបាយការណ៍គោរពជម្រាបជូនទៅ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចំពោះក្រសួង ស្ថាប័នណា ដែលមានការយឺតយ៉ាវ ឬខកខានការដំឡើងថ្នាក់ ឋានន្តរស័ក្តិនេះ។

សម្រាប់ការដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំបន្តបន្ទាប់ គ្រប់ក្រសួង ស្ថាប័ន ត្រូវផ្តល់សំណុំឯកសារឱ្យបាន **យ៉ាងយូរត្រឹមថ្ងៃទី ១៥ ខែ មករា រៀងរាល់ឆ្នាំ** ដើម្បីឱ្យក្រសួងមុខងារសាធារណៈ មានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យ និងផ្តល់ទិដ្ឋាការជូនបានទាន់ពេលវេលា។

ដោយឡែកចំពោះករណីមន្ត្រីរាជការដែលដល់អាយុចូលនិវត្តន៍នៅឆ្នាំបន្ទាប់ ការដំឡើងឋានន្តរស័ក្តិកិត្តិយស ក្រសួង ស្ថាប័ន ត្រូវលើកសំណើសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិដូចមានចែងក្នុងមាត្រា ៣២ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល មកក្រសួងមុខងារសាធារណៈ **យ៉ាងតិចមួយឆ្នាំមុន** ពេលចូលនិវត្តន៍ ដើម្បីឱ្យក្រសួងមុខងារសាធារណៈ មានពេលវេលាគ្រប់គ្រាន់ក្នុងការផ្តល់ទិដ្ឋាការបម្រែបម្រួលស្ថានភាពរដ្ឋបាល(បៀវត្ស) និងបោះពុម្ពសលាកប័ត្រចូលនិវត្តន៍ ឱ្យស្របតាមឋានន្តរសក្តិ និងថ្នាក់ចុងក្រោយរបស់និវត្តន៍ជន ។

" សូមជូនភ្ជាប់ជាមួយនូវតារាងគំរូការដំឡើងថ្នាក់ ឋានន្តរស័ក្តិ "

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នមេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ពេជ្រ ប៊ុនធិន**

<u>ចម្លងជូន</u>

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"

-គ្រប់រាជធានី ខេត្ត ដើម្បីសហការអនុវត្ត

-ឯកសារ-កាលប្បវត្តិ

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh